

# ការព្យាបាលផ្សេងៗ: កត្តាសំខាន់ ៗ

ស្ត្រីនិងមេរោគ HIV: ក្រដាស់ពត៌មានបន្តបន្ទាប់គ្នា សំរាប់ស្ត្រី ស្តីអំពីមេរោគ HIV



ការធ្វើតេស្តរកមើលមេរោគ HIV



ការទើបតែបានរកឃើញមានមេរោគថ្មីៗ



ការមើលថែទាំខ្លួនអ្នក



ការមានផ្ទៃពោះ និង ខ្ញុំ



កិច្ចបំរើផ្សេងៗ រដ្ឋ NSW និង គេហទំព័រ

## តើមានការព្យាបាលអ្វីខ្លះ?

មានថ្នាំព្យាបាលជាច្រើនដែលមានប្រសិទ្ធិភាពល្អ ក្នុងការព្យាបាល HIV។ ការព្យាបាលតាមធម្មតា គេហៅថា Antiretroviral Therapy (ART) ដែលមានរួម បញ្ចូលនូវថ្នាំ HIV បីឬច្រើនយ៉ាង។ គេក៏អាចហៅថា ARV (Antiretrovirals), HAART (Highly Active Antiretroviral Therapy) ឬការព្យាបាលរួមផ្សំនៃថ្នាំ (Combination Antiretroviral Therapy) ។

ថ្នាំទាំងនេះមិនព្យាបាល HIV ទេ តែវាធ្វើការកាត់បន្ថយនូវចំនួនមេរោគ HIV ដែលនៅក្នុងខ្លួនយើង។ វាបន្ថយល្បឿននូវការខូចខាតនៃប្រព័ន្ធ ប្រឆាំងនឹងមេរោគ ហើយជួយការពារនូវជំងឺ។

## ការតាមដានមើលថែសុខភាពលោកអ្នក

ទោះបីលោកអ្នកកំពុងធ្វើការព្យាបាលឬអត់ វាគឺជាសំខាន់ ដែលលោកអ្នកទៅជួបវេជ្ជបណ្ឌិត និងធ្វើតេស្តឈាមអោយបានទៀងទាត់ ជាទូទៅរាល់បីខែម្តង។

វេជ្ជបណ្ឌិតនឹងតាមដានពីមេរោគ HIV ដែលប៉ះពាល់ដល់ប្រព័ន្ធប្រឆាំងនឹងមេរោគ ដោយអោយធ្វើ តេស្តពីរយ៉ាង:

Viral load: ចំនួនមេរោគ គឺគេវាស់ចំនួនមេរោគ HIV ដែលមានក្នុងឈាម។ នៅពេលដែលចំនួនមេរោគធ្លាក់ដល់កំរិតទាប គេថា "រកមិនឃើញ"។នេះមិនមែនមានន័យថា មេរោគចេញអស់ពីខ្លួនទេ។

CD4 count: គឺជាការវាស់ចំនួន កោសិកា CD4 ដែលបង្ហាញពីចំនួនការខូចខាតនៃប្រព័ន្ធប្រឆាំងនឹងមេរោគដោយសារមេរោគ HIV។

គោលបំណងនៃការព្យាបាល គឺចង់សំរេចដល់ចំណុច "រកមិនឃើញ"ចំនួនមេរោគ និងបង្កើនកោសិកា CD4 ក៏ដូចការបង្កើនប្រព័ន្ធប្រឆាំងនឹងមេរោគ របស់លោកអ្នក ។

## ការចាប់ផ្តើមធ្វើការព្យាបាល

មានគោលការណ៍ជាច្រើនដែលបញ្ជាក់ពីពេលវេលាល្អ ក្នុងការចាប់ផ្តើមធ្វើការព្យាបាល ហើយវេជ្ជបណ្ឌិត នឹងពិភាក្សាជាមួយលោកអ្នកដើម្បីរក ពេលដែលល្អបំផុត។ ការចាប់ផ្តើមធ្វើការព្យាបាលគឺជាការសំរេចចិត្តដ៏ធំមួយ ដែលលោកអ្នកគួរតែធ្វើ ទាំងអស់គ្នា។ ដូច្នេះហើយបានជា ចំណងមិត្តភាព ជាមួយវេជ្ជបណ្ឌិតជាការសំខាន់។ ស្វែងរកជំរើស នៃការព្យាបាល ហើយកុំភ្លេចសួរវេជ្ជបណ្ឌិតនូវអ្វីៗដែលលោកអ្នកចង់ដឹង ។ លោកអ្នកត្រូវទទួលពត៌មាន និងត្រូវធ្វើការសំរេចចិត្ត តាមការងាយស្រួលសំរាប់អ្នកសំរួល។

## ការអនុវត្តតាម

ដើម្បីអោយការព្យាបាលប្រព្រឹត្តទៅបានល្អ គេត្រូវតែអនុវត្តតាមវេជ្ជបញ្ជាទាំងស្រុង។ នេះគេហៅថា "ការអនុវត្តតាម" ហើយមានន័យថាប្រើថ្នាំ:

- តាមចំនួនត្រឹមត្រូវ
- តាមពេលត្រឹមត្រូវ
- ធ្វើតាមដំបូន្មានអំពីម្ហូបអាហារនិងភេសជ្ជៈ
- ដោយមិនអាចភ្លេចថ្នាំណាឡើយ

លោកអ្នកត្រូវតែយល់អោយច្បាស់ អំពីរបៀបប្រើ ប្រាស់ថ្នាំ។

## ការធ្វើទុក្ខនៃថ្នាំ ឬប្រតិកម្មថ្នាំ

លោកអ្នកប្រហែលជាធ្លាប់មានបទពិសោធន៍ ពីការធ្វើទុក្ខនៃថ្នាំ។ ការធ្វើទុក្ខនេះ ភាគច្រើននឹងបាត់ទៅវិញបន្ទាប់ពី ពីរ បី សប្តាហ៍កន្លងទៅ។ ចូរពិគ្រោះជាមួយវេជ្ជបណ្ឌិតរបស់អ្នកដើម្បីរកវិធីទប់ទល់ នឹងបញ្ហាហ្នឹង។ ចូរកុំឈប់ប្រើថ្នាំដោយមិនពិភាក្សា ជាមួយវេជ្ជបណ្ឌិត។ ការធ្វើទុក្ខរយៈ ពេលខ្លីភាគច្រើនមានដូចជា:

- ការរាគរូស
- ការឈឺក្បាល
- មានអារម្មណ៍មិនស្រួលខ្លួន/ការក្អួតចង្អោរ
- ការឈឺពោះ

FAMILY PLANNING NSW
www.fpnsw.org.au
acon BUILDING OUR COMMUNITY'S HEALTH & WELLBEING
Multicultural HIV/AIDS and Hepatitis C Service
HIV + HETEROSEXUALS
ពត៌មាននេះធ្វើឡើងដោយ FPNSW និងការចូលរួមពី MHAHS, ACON និង HHAS នាខែ មិថុនា 2009

- ការចេញគ្រាប់កន្ទួលលើស្បែក
- ឬសុបិនចម្លែក ការធ្វើទុក្ខខ្លះ គ្រាន់តែកើតឡើងរយៈពេលខ្លីឬកើតឡើងក្រោយពេលលោកអ្នកធ្វើការព្យាបាលយូរបន្តិចមក។ វេជ្ជបណ្ឌិតនឹងតាមដានបញ្ហាទាំងនេះ។

## វិធីព្យាបាលបន្ថែម

ស្ត្រីជាច្រើនប្រើវិធីព្យាបាលបន្ថែមដើម្បី:

- ពង្រឹងប្រព័ន្ធប្រឆាំងនឹងមេរោគ
- ជួយពួកគេអោយស៊ាំនឹងការធ្វើទុក្ខ
- ការគ្រប់គ្រងភាពតានតឹង
- បង្កើនកម្លាំង

វិធីព្យាបាលបន្ថែមអាចមានដូចតទៅ:

- ការចាក់ម្ជុលវិទ្យាសាស្ត្រ
- ការប្រើថ្នាំចិនសៃ
- ការធ្វើសសៃ
- ការព្យាបាលដោយប្រើថ្នាំធម្មជាតិ

ជាការសំខាន់ដែល លោកអ្នកប្រាប់វេជ្ជបណ្ឌិតនូវរាល់វិធីព្យាបាលបន្ថែមណាដែលប្រើថ្នាំឬស ឈើ និងថ្នាំជំនួយខ្លះអាចប៉ះពាល់ដល់ថ្នាំ HIV លោកអ្នក។

## តើការព្យាបាលត្រូវអស់ប្រាក់ច្រើនទេ?

ការព្យាបាល HIV ភាគច្រើន ត្រូវបានជួយឧបត្ថម្ភខ្លះដោយរដ្ឋាភិបាល ប្រសិនបើលោកអ្នកមានប័ណ្ណ មេឌីឃែរ (Medicare card) មានន័យថាលោកអ្នក ត្រូវបង់ប្រាក់តែមួយចំនួនតូចប៉ុណ្ណោះ។

បើសិនលោកអ្នកមានប័ណ (Health Care) ឬប័ណ្ណ Pension លោកអ្នកអាចទទួលនូវការចុះថ្លៃបន្ថែមទៀត។ ប្រសិនបើលោកអ្នកបារម្ភពីបញ្ហាប្រាក់ កាស ចូរនិយាយទៅកាន់ វេជ្ជបណ្ឌិតឬបុគ្គិកជួយ គាំទ្រពីបញ្ហានេះ។ មានកិច្ចបំរើជាច្រើនដែលប្រហែលជាអាចជួយបាន។

## កិច្ចបំរើផ្សេងៗ

លោកអ្នកក៏អាចមើលរកកិច្ចបំរើរដ្ឋ NSW និងតាមគេហទំព័រជ្រាសពត៌មានការព្យាបាល

និងបុគ្គលិកជួយគាំទ្រអតិថិជន ACON Treatments and Client Support Officer ACON ទូរស័ព្ទ: (02) 9699 8756

BGF (Bobby Goldsmith Foundation) ផ្តល់ជំនួយផ្សេងៗ និង ជំនួយប្រាក់កាក់ (Practical and financial support) www.bgf.org.au ទូរស័ព្ទដោយឥតគិតថ្លៃ: 1800 651 011

ប្រសិនបើលោកត្រូវការអ្នកបកប្រែ សូមទូរស័ព្ទលេខ: 131 450

សំរាប់ការអានបន្ថែម: សូមបើកគេហទំព័រខាងក្រោម ឬសួររកឯកសារពីបុគ្គលិកជួយគាំទ្រទទួលការថែទាំដ៏ល្អបំផុតផ្នែក HIV (Getting the best HIV care) http://treataware.info/files/checklistguide.pdf

ការមើលថែទាំខ្លួនអោយបានត្រឹមត្រូវ (Treat yourself right)
http://www.afao.org.au/library_docs/resources/TYR_07.pdf

# ការព្យាបាលផ្សេងៗ: កត្តាសំខាន់ ៗ



ស្ត្រីនិងមេរោគ **HIV**: ក្រដាស់ពត៌មានបន្តបន្ទាប់គ្នា សំរាប់ស្ត្រី ស្ត្រីអំពីមេរោគ **HIV**

ពត៌មាននេះធ្វើឡើងដោយ FPNSW និងការចូលរួមពី MHAHS, ACON និង HHAS នាខែ មិថុនា 2009